# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ឯកសារបកប្រែ |
| --- |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 03-Aug-2011, 08:28 |
| CMS/CFO: Phok Chanthan |

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ**/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹង សំណើរបស់ "សហព្រះរាជអាជ្ញា" សុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មី ទាក់ទងទៅនឹងអង្គហេតុដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ជាជាងក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងជាជា អំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅវិញ**

---

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោកស្រី អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅសៀង

លោកស្រី Diana ELLIS, QC

ដាក់ជូន៖

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម ធូ មណី

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម យ៉ា សុខន

| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | **សហព្រះរាជអាជ្ញា៖** |
|---|---|
| លោក ពេជ អង្គ | លោកស្រី ជា លាង |
| លោកស្រី Elisabeth SIMONNEAU FORT | លោក Andrew CAYLEY |

# I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលក្នុងសាលដីកានេះ អង្គបុរេជំនុំជម្រះបានសម្រេចថា នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ អំពើរំលោភសេពសន្ថវៈមិនមែនជាបទល្មើសដោយផ្ទាល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ និងបានសម្រេច "ដកបទរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ នៃដីកាដំណោះស្រាយ និងរក្សាការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"[១]។ បន្ទាប់មក អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចដោយមានសំអាងហេតុរបស់ខ្លួន (**សាលដីកា របស់ អ.ប.ជ**)[២]។

២. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាខ្លួនឯងថាបានទទួលសំណុំរឿងលេខ ០០២[៣] ហើយ។ នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អនុលោមតាមវិធាន ៨០(១) និង(២) និងវិធាន ៨៩ នៃវិធានផ្ទៃក្នុង កាលបរិច្ឆេទផុតកំណត់ដែលបានកំណត់សម្រាប់ការដាក់អញ្ញត្រកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺនៅថ្ងៃ ច័ន្ទ ទី ១៤ ខែ កុម្ភៈ[៤]។ យោងតាមការជូនដំណឹងជាមុនរបស់អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ (**មេធាវីការពារក្តី**) បានដាក់ការ

---

[១] អ.ប.ជ៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12 ទំព័រ ៦។

[២] អ.ប.ជ៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៩ ដល់ ១៥៤។

[៣] អ.ជ.ស.ដ៖ ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9។

[៤] អ.ជ.ស.ដ៖ ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E35។

ជំទាស់តវ៉ារបស់ខ្លួនអំពីយុត្តាធិការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១[៥]។ បន្ទាប់ពីការសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយរួចមក សហព្រះរាជអាជ្ញាមិនបានដាក់អញ្ញត្រកម្មណាមួយទេ នៅក្នុងអំឡុងពេលដែលកំណត់ដោយ វិធាន ៨៩(១) នៃវិធានផ្ទៃក្នុងនោះ។

៣. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួនសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ឡើងវិញនូវអង្គហេតុដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ (សំណើរបស់ ក.ស.ព)[៦] ដោយស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ឡើងវិញនូវអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងទៅនឹងអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើរំលោភសេពសន្ថវៈ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ[៧]។

៤. នៅក្នុងសវនាការបឋមកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់មេធាវីការពារក្តីថា កាលបរិច្ឆេទផុតកំណត់សម្រាប់ការឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព ត្រូវបានពន្យារដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១[៨]។ ហេតុដូច្នេះ មេធាវីការពារក្តីសូមដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់ ក.ស.ព។

## II. បទប្បញ្ញត្តិច្បាប់

---

[៥] អញ្ញត្រកម្មរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E44។

[៦] ក.ស.ព៖ សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ឡើងវិញនូវអង្គហេតុដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E99។

[៧] សំណើរបស់ ក.ស.ព កថាខណ្ឌ ៣៣។

[៨] ប្រតិចារិកនៃសវនាការកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1 ទំព័រ ៣១ ដែលបានបញ្ជាក់នៅក្នុងសេចក្តីសេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំពន្យារពេល ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E 107។

៩. មេធាវីការពារក្តីសូមដាក់ជូននូវបទប្បញ្ញត្តិច្បាប់ដូចខាងក្រោម ដែលមានការពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចលើសំណើសុំដែលបានលើកឡើងនេះ៖

**វិធាន ៨៩ នៃវិធានផ្ទៃក្នុង ស្តីពី អញ្ញត្រកម្ម**

១. អញ្ញត្រកម្មទាក់ទងទៅនឹង៖

ក) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

ខ) ការរលត់បណ្តឹងអាជ្ញា

គ) មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ ត្រូវលើកឡើងយ៉ាងយូរ ៣0 (សាមសិប) ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនត្រូវបានទទួលយកឡើយ ។

២. អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្តល់ឱ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម។

៣. អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្ម តាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬ នៅពេលជំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ នៅក្នុងករណីដែលអញ្ញត្រកម្ម ត្រូវបានសម្រេចក្នុងពេលជំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី កិច្ចដំណើរការនីតិវិធីត្រូវធ្វើបន្ត ។

**វិធាន ៩២ នៃវិធានផ្ទៃក្នុង ស្តីពី ការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ**

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះត្រូវចុះហត្ថលេខា និង ចុះកាលបរិច្ឆេទទទួលសេចក្តីសន្និដ្ឋាននេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។

**វិធាន ៩៨(២)**

សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ

ជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែ មិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ។ អង្គជំនុំជម្រះត្រូវធ្វើការវិនិច្ឆ័យតែចំពោះជនជាប់ចោទប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាមួយ ដែលមកបង្ហាញខ្លួនក្នុងពេលជំនុំជម្រះក្នុងឋានៈជាសាក្សី ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬបានសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ អង្គជំនុំជម្រះនឹងធ្វើការជំនុំជម្រះលើបុគ្គលនោះបានលុះត្រាតែនៅក្រោយពេលដែលជននោះត្រូវបានចោទប្រកាន់ និងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះតែប៉ុណ្ណោះ។

## III. ភាពមិនអាចទទួលយកបាននៃសំណើរបស់ ក.ស.ព

### ៣.១ ភាពមិនអាចទទួលយកបាន៖ អញ្ញត្រកម្ម

៦. មេធាវីការពារក្ដីយល់ឃើញថា សំណើរបស់ ក.ស.ព មិនអាចទទួលយកបានទេ។ ទីមួយ សំណើរបស់ ក.ស.ព បង្កើតបានជាអញ្ញត្រកម្ម ដូច្នេះ សំណើនេះមិនអាចទទួលយកនៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធីបានទេ។ នៅក្នុងសេចក្ដីសម្រេច អ.ប.ជ អង្គបុរេជំនុំជម្រះបានអនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* (ad hoc) នៅក្នុងការកំណត់និយមន័យរបស់ខ្លួនទៅលើអ្វីដែលបង្កើតបានជាការជំទាស់តវ៉ាអំពីយុត្តាធិការ។ អង្គបុរេជំនុំជម្រះបានលើកឡើងយ៉ាងច្បាស់ថា "*ការជំទាស់ទៅនឹងបទល្មើសជាសារធាតុដែលត្រូវបានចោទប្រកាន់តាមមាត្រា ៣ (ថ្មី) ដល់មាត្រា ៨ នៃច្បាប់បង្កើត អ.វ.ត.ក*" បង្កើតបានឲ្យមានការជំទាស់យុត្តាធិការ "*នៅពេលដែលមានបណ្ដឹងតវ៉ាទៅនឹងអត្ថិភាពអង្គច្បាប់នៃបទល្មើស និងធាតុផ្សំនៃបទឧក្រិដ្ឋ នៅពេលដែលចោទប្រកាន់*"[៥] ។ សំណើរបស់សហព្រះរាជអាជ្ញាបង្កើតបានជាអញ្ញត្រកម្ម ដូចដែលបានកំណត់ដោយវិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ ដូចបានកំណត់ដោយដីកាដំណោះស្រាយដែលបានកែប្រែរួចហើយ។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែយុត្តាធិការរបស់ អ.វ.ត.ក ដើម្បីឲ្យបទរំលោភសេពសន្ថវៈក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយយ *ផ្ទាល់តែម្ដង* (per se) ជាជាងដាក់បញ្ចូលបទរំលោភសេពសន្ថវៈឲ្យស្ថិតនៅក្នុងចង្កោមនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៃឧក្រិដ្ឋកម្ម

---

[៥] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ៦១។

ប្រឆាំងមនុស្សជាតិទៅវិញនោះ។

៧. កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ នៅក្នុងការជូនដំណឹងជាមុនរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ថា អនុលោមតាមដីកាបង្គាប់របស់អង្គជំនុំជម្រះឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ នោះកាលបរិច្ឆេទចុងក្រោយដែលអាចអនុវត្តបានសម្រាប់ការដាក់អញ្ញត្រកម្ម គឺនៅថ្ងៃ ច័ន្ទ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលជាពេលវេលាកំណត់ក្នុងវិធាន ៨០(១) និង (២) និងវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដែលចាប់ផ្តើមរាប់ពីថ្ងៃសុក្រ ទី១៤ ខែ មករា ឆ្នាំ ២០១១[១០]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ច្បាស់ហើយថា ខ្លួននឹងបដិសេធសំណើទាំងអស់ដើម្បីឱ្យស្របទៅនឹងនីតិវិធីដែលបានធ្វើវិសោធនកម្ម ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងបច្ចុប្បនេះ[១១]។

៨. សហព្រះរាជអាជ្ញាមិនបានដាក់អញ្ញត្រកម្មណាមួយនៅមុនថ្ងៃ ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ទេ ហើយដូច្នេះមិនបានលើកឡើងអំពីការជំទាស់តវ៉ាទៅនឹងយុត្តាធិការណាមួយទៅលើការអនុវត្តបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ដោយផ្ទាល់* នៅចំពោះមុខ អ.វ.ត.ក នោះទេ។ តាមរយៈការមិនជំទាស់តវ៉ានេះ សហព្រះរាជអាជ្ញាបានព្រមទទួលយកការបកស្រាយអំពីបញ្ហាយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើបទល្មើស នៅក្នុងដីកាដំណោះស្រាយដែលបានកែប្រែរួចមកហើយនេះ។ នៅពេលនេះ សហព្រះរាជអាជ្ញាមិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរជំហររបស់ខ្លួននៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី ហើយស្នើសុំឱ្យអង្គជំនុំជម្រះពង្រីកយុត្តាធិការរបស់ខ្លួននោះទេ។ ពេលវេលាមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់សំណើសុំទៀតទេ។ ការកំណត់ពេលវេលាសម្រាប់ការដាក់អញ្ញត្រកម្មបានកន្លងផុតទៅជាយូរមកហើយ ហើយសំណើរបស់ ក.ស.ព គួរត្រូវបានច្រានចោល ដោយយោងទៅលើមូលដ្ឋាននេះតែមួយគត់។ ការអនុញ្ញាតយកសំណើសុំរបស់ ក.ស.ព មកពិចារណានៅក្នុងដំណាក់កាលនេះ គឺមិនមានន័យអ្វីចំពោះគោលបំណងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានលើកឡើងយ៉ាងច្បាស់ចំពោះការ

---

[១០] អ.ជ.ស.ដ៖ ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E35។

[១១] អ.ជ.ស.ដ៖ ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E35 ទំព័រ ២។

បដិសេធរាល់សំណើសុំ ដែលបានដាក់មិនស្របតាមនីតិវិធីដែលបានចែងរួចហើយនោះ[១២]។

៩. លើសពីនេះទៀត ក្រៅពីអង្គហេតុដែលថា សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីជំហររបស់មេធាវីការពារក្ដីតាមរយៈ "ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាអង្គច្បាប់ ដែលខ្លួនមានបំណងលើកនៅសវនាការបឋម[១៣]" សហព្រះរាជអាជ្ញាបានខកខានមិនបានផ្ដល់ការពន្យល់ ឬយុត្តិកម្មណាមួយចំពោះការដាក់អញ្ញត្រកម្មដែលហួសពេលរបស់ខ្លួនទេ[១៤]។ នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាគ្រាន់តែបញ្ជាក់ពីនៅក្នុងលេខយោងជើងទំព័រមួយថា សំណើរបស់ខ្លួនមិនមែនជាការជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ និងថាការកំណត់បទចោទឡើងវិញតាមផ្លូវច្បាប់ទាក់ទងនឹងអង្គហេតុ គឺមិនមែនវិធាន ៨៩ នៃវិធានផ្ទៃក្នុងស្ដីពីអញ្ញត្រកម្មដោយអង្គជំនុំជម្រះសាលាដំបូង[១៥] ដោយមិនបានផ្ដល់យុត្តិកម្មបន្ថែមទៀតដល់ភាគីនោះទេ។ ការខកខាននេះបញ្ជាក់ថា សហព្រះរាជអាជ្ញាបានសម្រេចដោយចេតនាមិនលើកឡើងអំពីបញ្ហានេះឲ្យទាន់ពេលវេលា ដែលគួរតែធ្វើឲ្យសំណើសុំនេះមិនអាចទទួលយកបានទេ។

### ៣.២ ភាពមិនអាចទទួលយកបាន៖ សំណើរបស់ ក.ស.ព មិនមានមូលដ្ឋានច្បាប់ទេ

១០. លើសពីនេះទៀត ក.ស.ព បានលើកឡើងថា សំណើរបស់ខ្លួនស្ថិតនៅក្រោមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្ដីសូមច្រានចោលការបកស្រាយនេះ។ ក.ស.ព បានស្នើសុំឲ្យ

---

[១២] អ.ជ.ស.ជ៖ ការជូនដំណឹងជាមុនអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E35 ទំព័រ ២។

[១៣] ការអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E9/30/1 កថាខណ្ឌ ៣ ដល់ ៦។

[១៤] ក.ស.ព៖ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការកត់សម្គាល់របស់មេធាវីការពារក្ដី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ ដែលសហព្រះរាជអាជ្ញាមានបំណងលើកឡើងនៅក្នុងសវនាការបឋម ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E9/30/2។

[១៥] សំណើរបស់ ក.ស.ព លេខយោងជើងទំព័រ ១៣។

អង្គជំនុំជម្រះកែប្រែច្បាប់ និងយុត្តាធិការរបស់អង្គជំនុំជម្រះទៅលើបទល្មើសដែលបានចោទប្រកាន់។ ការស្នើសុំនេះមិនមែនគ្រាន់តែជាការស្នើសុំឲ្យកំណត់បទចោទឡើងវិញចំពោះអង្គហេតុដូចមានចែងក្នុងវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងនោះទេ។ សហព្រះរាជអាជ្ញាកាន់តែទៅឆ្ងាយជាងនេះទៅទៀត និងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ច្រានចោលបទរំលោភសេពសន្ថវៈ ដែលជាអំពើអមនុស្សធម៌មួយបង្កបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយផ្ទុយទៅវិញ បានកំណត់អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ដោយផ្ទាល់*[១៦] បើទោះជាអង្គបុរេជំនុំជម្រះបានយល់ឃើញថា បទរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ដោយផ្ទាល់*មិនបានមានអត្ថិភាពនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ នោះទេ។ យន្តការតែមួយគត់សម្រាប់ការជំទាស់តវ៉ាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង គឺការដាក់អញ្ញត្រកម្មស្តីពីយុត្តាធិការរបស់ អ.វ.ត.ក ដោយអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ មូលដ្ឋានច្បាប់ដែលលើកឡើងដោយសហព្រះរាជអាជ្ញាសម្រាប់សំណើរបស់ខ្លួន គឺមិនមានសុពលភាពនោះទេ ហើយដូច្នេះ សំណើរបស់ ក.ស.ព គួរតែត្រូវបានបដិសេធចោល។

## ៣.៣ ភាពមិនអាចទទួលយកបាន៖ មិនមានការប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ

១១. នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ អ.ប.ជ ចំពោះការមិនផ្តន្ទាទោសបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩[១៧]។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសវនាការកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ រួចមកហើយ មេធាវីការពារក្តីសូមរំលឹកឡើងវិញថា ភាគីមិនអាចស្នើសុំឲ្យពិនិត្យសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះឡើងវិញបានទេ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនត្រូវបានបង្កើតឡើងដោយវិធាន

---

[១៦] សំណើរបស់ ក.ស.ព ទំព័រ ៥។

[១៧] សំណើរបស់ ក.ស.ព កថាខណ្ឌ ៦ ដែលសហព្រះរាជអាជ្ញាបានបានអះអាងថា “ទស្សនទានស្តីពីអំពើរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតមានមានឡើងពិតប្រាកដនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥ [...]”។

ផ្ទៃក្នុងថាជាសាលាឧទ្ធរណ៍នោះដែរ[១៨]។ នីតិវិធីតែមួយគត់ដែលបើកឲ្យសហព្រះរាជអាជ្ញាជំទាស់ទៅនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់នៅក្នុងសេចក្ដីសម្រេច អ.ប.ជ គឺការដាក់អញ្ញត្រកម្មនៅមុនថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលសហព្រះរាជអាជ្ញាខកខានមិនបានធ្វើដូច្នេះទេ។

## IV. សារណា

### ៤.១ "ការកំណត់អង្គហេតុឡើងវិញតាមផ្លូវច្បាប់" គឺមិនមែនជា "ការកំណត់បទល្មើសឡើងវិញ" នោះទេ

១២. ដោយអនុលោមតាមវិធានផ្ទៃក្នុង ៩៨(២) ក.ស.ព បានស្នើសុំឱ្យអង្គជំនុំជម្រះកំណត់បទល្មើសឡើងវិញទាក់ទងនឹងអង្គហេតុនានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីចោទប្រកាន់ជនជាប់ចោទពីបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាជាងដាក់បទចោទនេះនៅក្រោមអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៩]។ នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានផ្អែកលើការបកស្រាយមិនត្រឹមត្រូវនៃពាក្យថា "ការកំណត់បទល្មើសឡើងវិញតាមផ្លូវច្បាប់" ដូចបានចែងនៅក្នុងវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ វិធានមួយនេះពាក់ព័ន្ធតែទៅនឹងការកំណត់បទល្មើសតាមផ្លូវច្បាប់ឡើងវិញ ទាក់ទងនឹងអង្គហេតុតែប៉ុណ្ណោះ មិនមែនពាក់ព័ន្ធទៅនឹងការកំណត់បទចោទតាមផ្លូវច្បាប់ឡើងវិញក្នុងគោលបំណងបន្ថែមបទឧក្រិដ្ឋថ្មីណាមួយទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។

១៣. លេខយោងជើងទំព័រ លេខ ១២ នៃសំណើរបស់ ក.ស.ព យោងទៅលើករណីមួយចំនួន ដែលមាននៅតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប។ ការកំណត់បទល្មើសឡើងវិញដែលត្រូវបានអនុញ្ញាតដោយតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបនេះ និងត្រូវបានយោងនៅក្នុងកថាខណ្ឌ ១០ ពាក់ព័ន្ធទៅនឹងការអនុវត្តបទប្បញ្ញត្តិច្បាប់ជាក់លាក់មួយទៅលើអង្គហេតុ ដែលមិនដូចទៅនឹងករណីនេះ ដែលមានការបកស្រាយតាមផ្លូវច្បាប់ឡើងវិញដើម្បីបន្ថែមបទចោទថ្មីនោះឡើយ។ សហព្រះរាជអាជ្ញាបក

---

[១៨] ប្រតិចារិកនៃសវនាការកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ឯកសារ E1/1.1 ទំព័រ ៤៧ ដល់ ៤៨។

[១៩] សំណើរបស់ ក.ស.ព កថាខណ្ឌ ១ និងកថាខណ្ឌ ៧។

ស្រាយខុសលើច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប នៅពេលដែលសហព្រះរាជអាជ្ញាលើកឡើងដោយយោងទៅយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបថា "ការកំណត់បទចោទឡើងវិញចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ត្រូវបានគេអនុញ្ញាត"[២០] ខណៈដែលយុត្តិសាស្ត្រដែលបានយោងនោះ ពាក់ព័ន្ធនឹងការកំណត់បទល្មើសឡើងវិញតាមផ្លូវច្បាប់ចំពោះ*អង្គហេតុ*[២១]។ ជាឧទាហរណ៍ ស្ថានភាពនៃតុលាការអឺរ៉ុបគឺនៅក្នុងសំណុំរឿង *I.H. និងអ្នកដទៃទៀត តទល់នឹង ប្រទេសអូទ្រីស*[២២] គឺជាការកំណត់ឡើងវិញនូវបទរំលោភសេពសន្ថវៈ ឱ្យទៅជាការរំលោភសេពសន្ថវៈក្រោមការគម្រាមកំហែងនៃអំពើហិង្សាធ្ងន់ធ្ងរ។ ហេតុដូច្នេះ យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបនេះ ដែលត្រូវបានយោងដោយសហព្រះរាជអាជ្ញា មិនបានគាំទ្រដល់សារណារបស់ខ្លួនឡើយ។

---

[២០] សំណើរបស់ ក.ស.ព កថាខណ្ឌ ១០។

[២១] សំណុំរឿង *Pélissier និង Sassi តទល់នឹង ប្រទេសបារាំង* ពាក្យសុំលេខ No. 25444/94 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦២ ដែលក្នុងនោះលើកឡើង ដែលពាក់ព័ន្ធទៅនឹងចំណុចនេះថា៖ "ហេតុដូច្នេះ តុលាការពិចារណាឃើញថា នៅក្នុងការប្រើប្រាស់សិទ្ធិ ដែលខ្លួនមានដោយមិនអាចជំទាស់បាន នៅក្នុងការកំណត់អង្គហេតុឡើងវិញ ដែលខ្លួនមានយុត្តាធិការលើបញ្ហានេះ តុលាការជាន់ខ្ពស់ Aix-en-Provence គួរតែត្រូវបានគាំទ្រដល់អ្នកដាក់ពាក្យសុំឱ្យមានលទ្ធភាពអនុវត្តសិទ្ធិការពារក្តីរបស់ខ្លួននៅក្នុងបញ្ហានេះបានយ៉ាងជាក់ស្តែងនិងមានប្រសិទ្ធិភាព ហើយជាពិសេស ស្ថិតនៅក្នុងពេលវេលាសមស្រប"។ សូមមើលផងដែរ សំណុំរឿង *Sipacivius តទល់នឹង Lithuania* ពាក្យសុំលេខ No. 49093/99 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ កថាខណ្ឌ ៣១ ដែលពាក់ព័ន្ធទៅនឹង "ការកំណត់បទចោទឡើងវិញ" ដែលនៅក្នុងសំណុំរឿងនេះ អ្នកដាក់ពាក្យប្តឹងជំទាស់ប្រឆាំងទៅនឹងនីតិវិធីពិនិត្យឡើងវិញ ថាមិនមានភាពគ្រប់គ្រាន់ ដែលការប្តឹងជំទាស់នេះមិនមែនប្រឆាំងនឹង "ការកំណត់បទចោទឡើងវិញ" នោះទេ។ សំណុំរឿងទីបីដែលមានរៀបរាប់នៅក្នុងសំណើរបស់ ក.ស.ព នៅត្រង់លេខយោងជើងទំព័រ លេខ១០ គឺសំណុំរឿង *I.H. និងអ្នកដទៃទៀត តទល់នឹង ប្រទេសអូទ្រីស* ពាក្យសុំលេខ No. 42780/98 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦។ ករណីនេះ ជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងការកំណត់អង្គហេតុឡើងវិញតាមផ្លូវច្បាប់ ដូចបានបង្ហាញនៅក្នុងកថាខណ្ឌ ៣៨ នៅក្នុងឯកសារនោះ។

[22] *I.H និងអ្នកដទៃទៀត ទល់នឹង ប្រទេសអូទ្រីស* Appl. No. 42780/98, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ ពីកថាខណ្ឌ ១៥ ដល់កថាខណ្ឌ ១៧

១៤. ការស្នើសុំឱ្យកំណត់ឡើងវិញនូវបទល្មើសនៃការរំលោភសេពសន្ថវៈ ដើម្បីបន្ថែមបទចោទថ្មីមួយប្រឆាំងនឹងជនជាប់ចោទ គឺជាការរំលោភបំពានយ៉ាងច្បាស់ក្រឡែតទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌មួយ។ សេចក្ដីសន្និដ្ឋានដែលសហព្រះរាជអាជ្ញាបានធ្វើឡើងថា ការចោទប្រកាន់បទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដ៏ជាក់លាក់មួយ ជាជាងជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិក្រោមអំពើអមនុស្សធម៌ដទៃទៀត គឺមិនមែនថាអយុត្តិធម៌ទេ[២៣] និងស្របតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទនោះ[២៤] មិនមានយុត្តិកម្មឡើយ។

១៥. សហព្រះរាជអាជ្ញាបន្តលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលត្រូវបានយោងពីខាងលើ គាំទ្រដល់គំនិតដែលថា "ការកំណត់បទចោទឡើងវិញណាមួយដែលអាចនឹងកើតមានឡើងនៅពេលប្រកាសសាលក្រម គឺពិតជាស្របទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ"[២៥] ដែលការលើកឡើងយ៉ាងដូច្នេះ គឺជាការមិនអើពើទៅលើអត្ថបទដែលត្រូវបានយោងពីខាងលើ ដែលហាមឃាត់សូម្បីតែការកំណត់អង្គហេតុឡើងវិញនៅក្នុងដំណាក់កាលយឺតយ៉ាវហួសហេតុ ហើយ ក៏ហាមឃាត់ផងដែរចំពោះករណីរបស់យើងនេះ ចំពោះការកំណត់អង្គច្បាប់ឡើងវិញតាមផ្លូវច្បាប់។ នៅក្នុងសំណុំរឿង *Pélissier និង Sassi តទល់នឹង ប្រទេសបារាំង* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា[២៦]៖

> សម្ភារៈនៅចំពោះមុខតុលាការបង្ហាញឱ្យឃើញថា អ្នកដាក់ពាក្យសុំមិនត្រូវបានផ្ដល់ឱកាសដើម្បីរៀបចំការការពារក្ដីរបស់ខ្លួនចំពោះបទចោទថ្មីនោះទេ ដោយសារហេតុថាពួកគាត់ទើបតែបានដឹងអំពីការកំណត់

---

[២៣] សំណុំរឿង *I.H. និង អ្នកដទៃទៀត តទល់នឹង ប្រទេសអូទ្រីស* ពាក្យសុំលេខ 42780/98 ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ១៥ ដល់កថាខណ្ឌ ១៧។

[២៤] សំណើរបស់ ក.ស.ព កថាខណ្ឌ ៧។

[២៥] សំណើរបស់ ក.ស.ព កថាខណ្ឌ ១០ ដល់កថាខណ្ឌ ១១។

[២៦] សំណើរបស់ ក.ស.ព កថាខណ្ឌ ១១។

បទល្មើសឡើងវិញចំពោះអង្គហេតុទាំងនេះ តាមរយៈសាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់តែប៉ុណ្ណោះ។ និយាយឱ្យងាយយល់ទៅ វាហួសពេលទៅហើយ។

១៦. ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា ការអនុវត្តបទបញ្ជា លេខ ៥៥ ដែលពាក់ព័ន្ធនឹងការកំណត់បទល្មើសឡើងវិញទាក់ទងនឹងអង្គហេតុ "ត្រូវកំហិតមកត្រឹមតែអង្គហេតុ និងកាលៈទេសៈទាំងឡាយណា ដែលត្រូវបានពណ៌នានៅក្នុងបទចោទ ឬនៅក្នុងវិសោធនកម្មនានា"[២៧]។

១៧. មេធាវីការពារក្តីសូមស្នើឡើងថា សហព្រះរាជអាជ្ញាបានច្រឡំបញ្ចូលគ្នាដោយមិនត្រឹមត្រូវនូវទស្សនទាននៃការកំណត់អង្គហេតុឡើងវិញតាមផ្លូវច្បាប់ និងការកំណត់ឡើងវិញនូវបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ក្នុងគោលបំណងបន្ថែមបទចោទថ្មី។ ទស្សនទាននៃការកំណត់អង្គហេតុឡើងវិញតាមផ្លូវច្បាប់ គាំទ្រដល់ទស្សនទាននៃការកំណត់ឡើងវិញនូវបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ហេតុដូច្នេះមិនអាចគាំទ្រដល់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ដែលថាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានកំណត់និយមន័យឡើងវិញនៅដំណាក់កាលនេះ ដើម្បីអនុញ្ញាតឱ្យមានការចោទប្រកាន់លើជនជាប់ចោទពីបទចោទថ្មីមួយ ដែលជាបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ *ដោយផ្ទាល់* (*per se*)។

## ៤.២ ទឡ្ហីករណ៍សំខាន់ៗ

១៨. សម្រាប់សំអាងហេតុដែលបានរៀបរាប់នៅទីនេះ មេធាវីការពារក្តីសូមស្នើឡើងថា សំណើរបស់ ក.ស.ព មិនអាចទទួលយកបាន និងគួរតែបដិសេធចោល ដោយសារកង្វះខាតមូលដ្ឋានអង្គច្បាប់។ ឥឡូវនេះ មេធាវីការពារក្តីសូមងាកទៅរៀបរាប់ខ្លឹមសារនានានៃទឡ្ហីករណ៍របស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងកថាខណ្ឌទី១២ ដល់ទី៣២ នៃសំណើរបស់ ក.ស.ព។

---

[២៧] សំណុំរឿង *Pélissier និង Sassi តទល់នឹង ប្រទេសបារាំង* ពាក្យសុំលេខ No. 25444/94 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦២។

### ៤.២.១ តើបទរំលោភសេពសន្ថវៈ ត្រូវបានកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬទេ គិតមកត្រឹមឆ្នាំ ១៩៧៥

១៩. ជាបឋម សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា បទរំលោភសេពសន្ថវៈត្រូវបានកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដោយឡែកមួយ គិតមកត្រឹមឆ្នាំ ១៩៧៥[២៨]។ ដើម្បីគាំទ្រដល់ការលើកឡើងនេះ សហព្រះរាជអាជ្ញាបានយោងទៅលើប្រភពច្បាប់មនុស្សធម៌អន្តរជាតិនានា ដែលត្រូវបានយោងរួចមកហើយដោយអង្គបុរេជំនុំជម្រះ[២៩] គណៈកម្មការឆ្នាំ ១៩១៩ ស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កើតឱ្យមានសង្គ្រាម និងការដាក់ទោសទណ្ឌ[៣០] ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០[៣១] ធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិ (IMT) នៅទីក្រុងនូរ៉េប៊ែរ និងធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិសម្រាប់ចុងបូព៌ា[៣២] លក្ខន្តិកៈសម្រាប់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) និង រ្វ៉ាន់ដា

---

[២៨] សំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06 **AO 15 AO 16 អង្គជំនុំជម្រះជាន់ខ្ពស់** សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ លោក Lubanga Dyilo និង រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ ដែលមានចំណងជើងថា “សេចក្តីសម្រេចផ្តល់សេចក្តីជូនដំណឹងដល់ភាគី និងអ្នកចូលរួម ថាការកំណត់អង្គហេតុនានាតាមផ្លូវច្បាប់ អាចមានការប្រែប្រួល ដោយអនុលោមតាមបទបញ្ជា លេខ ៥៥(២) នៃបទបញ្ជារបស់តុលាការ” ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៩១។

[២៩] សំណើរបស់ ក.ស.ព កថាខណ្ឌ ១២ ដល់កថាខណ្ឌ ២១។

[៣០] សំណើរបស់ ក.ស.ព កថាខណ្ឌ ២១ ដោយយោងទៅលើមាត្រា ៤៤ នៃក្រម Lieber ឆ្នាំ ១៨៦៣, បទបញ្ញាដែលជាឧបសម្ព័ន្ធរបស់អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩០៧ ដែលអានរួមគ្នាជាមួយនឹងឃ្លាបញ្ញត្តិ Martens, អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងយោងទៅលើពិធីការបន្ថែមទី I និងទី II ឆ្នាំ ១៩៧៧។

[៣១] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៣។

[៣២] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៤។

("ICTR")[៣៣] និងយោងទៅលើយុត្តិសាស្ត្ររបស់ ICTY, ICTR និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")[៣៤]។ មេធាវីការពារក្តីសូមលើកឡើងថា សហព្រះរាជអាជ្ញាមិនបានបង្ហាញឱ្យឃើញថា ការកំណត់បទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋ មានអត្ថិភាពជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៅមុនឆ្នាំ ១៩៧៥ ឬ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ ជាពិសេស សហព្រះរាជអាជ្ញាមិនបានផ្អែកលើប្រភពច្បាប់ថ្មីៗណាមួយ ក្រៅពីប្រភពច្បាប់ដែលត្រូវបានយោងនៅចំពោះមុខអង្គបុរេជំនុំជម្រះហើយនោះទេ។

២០. អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវថា លិខិតុបករណ៍នៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានប្រកាសមុនឆ្នាំ ១៩៤៥ ក៏ដូចជាអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមនានារបស់អនុសញ្ញានេះនៅឆ្នាំ១៩៧៧ គឺជាប្រភពច្បាប់ពាក់ព័ន្ធ ដែលបង្ហាញថាបទរំលោភសេពសន្ថវៈ មានអត្ថិភាពជាបទឧក្រិដ្ឋសង្គ្រាមមុនឆ្នាំ ១៩៧៥[៣៥] ប៉ុន្តែមិនមែនជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិឡើយ។

២១. មេធាវីការពារក្តីសូមរំឭកឡើងវិញថា "មិនមានយុត្តិសាស្ត្រច្បាស់លាស់ណាមួយ ស្តីអំពីការសម្រេចឱ្យមានទោសចំពោះបទរំលោភសេពសន្ថវៈ ដោយអនុលោមតាមច្បាប់នេះនៅចំពោះមុខតុលាការ IMTs នោះទេ"[៣៦]។ ដូចដែលបានគូសបញ្ជាក់យ៉ាងត្រឹមត្រូវដោយសហព្រះរាជអាជ្ញានៅក្នុងសំណើរបស់ខ្លួនហើយនោះ តុលាការ IMTs និងវដ្តធម្មនុញ្ញរបស់តុលាការនេះ មិនបានបញ្ចូលបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ*ដោយផ្ទាល់* (*per se*) នោះទេ[៣៧]។

---

[៣៣] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៥។

[៣៤] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៦។

[៣៥] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៧ ដល់កថាខណ្ឌ ១៩។

[៣៦] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៥១។

[៣៧] សាលដីការរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៥២។

សាលក្រមរបស់តុលាការ IMTs មិនបានលើកឡើងអំពីបទរំលោភសេពសន្ថវៈឡើយ ហើយមិនមានជនជាប់ចោទណាមួយត្រូវបានកំណត់ទោសពីបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនោះដែរ[៣៨]។ លើសពីនេះ មហាសន្និបាតអង្គការសហប្រជាជាតិ មិនបានអនុម័តថា ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ នៅក្នុងគោលការណ៍នូរ៉េប៊ែរនោះ។ ដូចដែលត្រូវបានសម្រេចយ៉ាងត្រឹមត្រូវដោយអង្គបុរេជំនុំជម្រះរួចហើយ តុលាការ IMT មិនបានបង្ហាញឱ្យឃើញថា បទរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែកមួយនៅមុនឆ្នាំ ១៩៧៥ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[៣៩]។

២២. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍បន្ថែមទៀតថា បទរំលោភសេពសន្ថវៈត្រូវបានចងក្រងថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដោយមានការអនុម័តលើលក្ខន្តិកៈរបស់ ICTR និង ICTY ហើយថា "ការរៀបរាប់ឈ្មោះឧក្រិដ្ឋកម្មនានានៅក្នុងលក្ខន្តិកៈទាំងនោះបានផ្អែកលើមូលដ្ឋាននៃការយល់ដឹងអំពីច្បាប់តាមទម្លាប់អន្តរជាតិ *នៅមុនពេល* មានការអនុម័តលក្ខន្តិកៈទាំងនោះ"[៤០]។ សហព្រះរាជអាជ្ញាមិនបានយោងទៅលើសំអាងផ្លូវច្បាប់នានាដែលអាចបង្ហាញថា បទរំលោភសេពសន្ថវៈ មានអត្ថិភាពជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់ នៅមុនឆ្នាំ ១៩៧៥ ឬ នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលជាបញ្ហានៅចំពោះមុខនេះ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានយោងទៅលើលក្ខន្តិកៈដែលត្រូវបានអនុម័តអស់រយៈពេលប្រមាណ២០ឆ្នាំ បន្ទាប់ពីការចាប់ផ្តើមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នេះទៅវិញ។ សហព្រះរាជអាជ្ញាជំរុញឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមយុត្តិសាស្ត្រដែលមាននៅ

---

[៣៨] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៥។

[៣៩] សូមមើលឯកសាររបស់ Kelly D. Askin "Prosecuting Wartime Rape and Other Gender-Related Crimes under International Law: Extraordinary Advances, Enduring Obstacles" បោះពុម្ពឆ្នាំ ២០០៣ លេខ ២១ នៅក្នុងព្រឹត្តិប័ត្រ *Berkeley Journal of International Law* 288, 301។

[៤០] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៥២។

Original EN: 00716118-00716133

តុលាការព្រហ្មទណ្ឌអន្តរជាតិនានាសម្រាប់ប្រទេសរ៉្វាន់ដា និងសម្រាប់ប្រទេសយូហ្គោស្លាវី និង តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន[៤១] ដែលបានទទួលស្គាល់ការរំលោភសេពសន្ថវៈ ថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់ នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ និងដើម សហសវត្សរ៍ឆ្នាំ ២000។ ជាថ្មីម្តងទៀត មេធាវីការពារក្តីសូមរំឭកឡើងវិញថា លក្ខន្តិកៈរបស់ តុលាការទាំងនេះ ត្រូវបានធ្វើពង្រាងអស់រយៈពេលប្រមាណ ៣៥ឆ្នាំ បន្ទាប់ពីការប្រព្រឹត្តិឧក្រិដ្ឋ-កម្មនានាដែលត្រូវបានចោទ ហើយលក្ខន្តិកៈទាំងនេះមិនឆ្លុះបញ្ចាំងនូវស្ថានភាពច្បាប់ នៅក្នុងអំឡុង ចន្លោះពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ។

២៣. សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា "ដោយសារមិនមានការរីកចំរើនដែលពាក់ព័ន្ធទៅនឹង ច្បាប់តាមទម្លាប់អន្តរជាតិទាក់ទងទៅនឹងបទរំលោភសេពសន្ថវៈ ក្នុងអំឡុងចន្លោះពេលយុត្តាធិការ របស់ អ.វ.ត.ក ហើយនិងតុលាការពិសេសនានានោះ ការរកឃើញរបស់ អ.វ.ត.ក ដែលថា បទរំលោភសេពសន្ថវៈមិនមែនជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងឆ្នាំ ១៩៧៥-៧៩ គឺន័យថា ការរកឃើញរបស់តុលាការពិសេសនានា ថាបទរំលោភសេពសន្ថវៈ គឺជា ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិនោះ គឺជាការខុសឆ្គង"[៤២]។ មេធាវីការពារក្តីសូមលើកឡើងថា ការអះអាង បែបនេះ គឺមិនត្រឹមត្រូវទេ។ តុលាការ *មិនអចិន្ត្រៃយ៍* (*ad hoc*) បានយល់ឃើញថា ការរំលោភ សេពសន្ថវៈគឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ តុលាការទាំងនោះ ដែលអំឡុងពេលនោះគឺស្ថិតនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ការប្រកាសថា បទរំលោភសេពសន្ថវៈមិនមានអត្ថិភាពនៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ថាជាបទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់នោះ មិនមានន័យថា តុលាការ *មិនអចិន្ត្រៃយ៍* មាន កំហុសឆ្គងនោះទេ នៅពេលដែលខ្លួនសម្រេចលើបញ្ហានេះនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ នោះទេ។

---

[៤១] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៦។

[៤២] សំណើរបស់ ក.ស.ព កថាខណ្ឌ ១៨។

ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាគួរត្រូវបានច្រានចោល ដោយមូលហេតុថា ទឡ្ហីករណ៍នេះមិនសមហេតុផល ឬមិនមានភាពត្រឹមត្រូវ។

២៤. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ដើម្បីបង្កើននូវភាពយុត្តិធម៌ និងជៀសវាងនូវភាពមិនច្បាស់លាស់នៅក្នុងច្បាប់ អង្គជំនុំជម្រះសាលាដំបូងគួរតែអនុវត្តតាមសេចក្តីសម្រេចទាំងឡាយរបស់តុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការអន្តរជាតិនានា[៤៣]។ មេធាវីការពារក្តីសូមកត់សម្គាល់ជាថ្មីម្តងទៀតថា យុត្តាធិការពេលវេលារបស់តុលាការទាំងនោះ មានភាពខុសៗគ្នា ហើយបានចាប់ផ្តើមសំណុំរឿងនីមួយៗនៅក្រោយពេលវេលាដែលគ្របដណ្តប់ដោយយុត្តាធិការរបស់ អ.វ.ត.ក។ យុត្តិសាស្ត្រពីតុលាការអន្តរជាតិ និងតុលាការដែលមានលក្ខណៈជាអន្តរជាតិទាំងនោះ ឆ្លុះបញ្ចាំងពីកាលៈទេសៈពិសេសៗតុលាការទាំងនោះ។ ដូចដែលមេធាវីបានលើកឡើងនៅក្នុង "ការឆ្លើយតបរបស់មេធាវីការពារក្តីទៅកាន់ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" "ការផ្អែកទៅលើសេចក្តីសម្រេចនានា ដែលបានប្រកាសអស់រយៈពេល ២០ឆ្នាំ បន្ទាប់ពីការចាប់ផ្តើមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក អាចនឹងមិនឆ្លុះបញ្ចាំងនូវស្ថានភាពអង្គច្បាប់នៅក្នុងឆ្នាំ ១៩៧៥ នោះទេ ហើយជាលទ្ធផលការធ្វើបែបនេះ គម្រាមកំហែងដល់គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង *nullum crimen sine lege*"[៤៤]។ អ.វ.ត.ក មានយុត្តាធិការលើបទល្មើសទាំងឡាយណា ដែលត្រូវបានចោទថាត្រូវបានប្រព្រឹត្តនៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ខណៈដែលតុលាការការ *មិនអចិន្ត្រៃយ៍* នានា ក៏ដូចជាតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន មានយុត្តាធិការលើបទល្មើសទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនាពេលកន្លងទៅថ្មីៗជាងនេះ។ ហេតុដូច្នេះ ស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ មិនអាចត្រូវបានយល់ថាដូចគ្នាទៅនឹងច្បាប់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០នោះឡើយ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនគួរសម្រេចលើបញ្ហានៅ

[៤៣] សំណើរបស់ ក.ស.ព កថាខណ្ឌ ២១។

[៤៤] សំណើរបស់ ក.ស.ព កថាខណ្ឌ ២១។

Original EN: 00716118-00716133

ចំពោះមុខនាពេលបច្ចុប្បន្ននេះ ដោយផ្អែកតែទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ដែលមិនឆ្លុះបញ្ចាំងអំពីស្ថានភាពច្បាប់ក្នុងអំឡុងពេលនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទថាត្រូវបានប្រព្រឹត្តនោះទេ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាមិនបានពន្យល់អំពីមូលដ្ឋាននៃការអះអាងរបស់ខ្លួនដែលថា "តុលាការអន្តរជាតិដទៃទៀតពិចារណាឃើញថា យុត្តិសាស្ត្រអន្តរជាតិមុនៗលើបញ្ហានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាប្រភពច្បាប់ដ៏មានឥទ្ធិពល"[៤៥] ប៉ុន្តែនាពេលនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើយុត្តិសាស្ត្រអន្តរជាតិដែលមាននាពេល*ក្រោយៗ*ទៅវិញ។

២៥. លោក M. Cherif Bassiouni (*ឆែរីហ្វ បាស៊ីយ៉ូនី*) បានលើកទឡ្ហីករណ៍នៅក្នុងសៀវភៅរបស់គាត់ដែលបោះពុម្ពនៅក្នុងឆ្នាំ ១៩៩៩ ថា ការរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*ដោយខ្លួនឯងផ្ទាល់ (per se)* នោះទេ ប៉ុន្តែការរំលោភសេពសន្ថវៈនេះបង្កើតបានជា "អំពើអមនុស្សធម៌ដទៃទៀត" នៅក្រោមគោលការណ៍ទូទៅនៃច្បាប់[៤៦]។ ហេតុដូច្នេះ នៅក្នុងឆ្នាំ ១៩៧៦ គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសម្រេចថា ការរំលោភសេពសន្ថវៈដែលមានលក្ខណៈរាលដាលនៅក្នុងអំឡុងពេលជម្លោះអន្តរជាតិណាមួយ បង្កើតបានជាអំពើធ្វើបាបដ៏អមនុស្សធម៌ក្រោមមាត្រា ៣ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប[៤៧]។ ដូចនេះ លោក Bassiouni ផ្តល់ឱ្យនូវការគាំទ្របន្ថែមទៀតសម្រាប់ការបដិសេធចោលនូវសំណើររបស់សហព្រះរាជអាជ្ញា។

---

[៤៥] ការឆ្លើយតបរបស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ ទៅកាន់ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ D427/2/11 (ការឆ្លើយតបរបស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ) កថាខណ្ឌ ៤៣។

[៤៦] សំណើររបស់ ក.ស.ព លេខយោងជើងទំព័រ លេខ ៣៧។

[៤៧] ឯកសាររបស់ M. Cherif Bassiouni ស្តីអំពី *Crimes Against Humanity in International Criminal Law* បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៩៩ ទំព័រ ៣៥៤។

### ៤.២.២ តើជនជាប់ចោទអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងថា ការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែរឬទេ

២៦. ជាដំបូង សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍ថា "ការហាមឃាត់នៃការរំលោភសេពសន្ថវៈនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបង្កើតឡើងយ៉ាងគ្រប់គ្រាន់ គិតមកត្រឹមឆ្នាំ ១៩៧៥ ដែលជនជាប់ចោទគួរតែអាចព្យាករណ៍ទុកមុនបានថា អំពើទាំងឡាយនៃការរំលោភសេពសន្ថវៈ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ហើយថា "ការណ៍ដែលថាឧក្រិដ្ឋកម្មនេះ អាចត្រូវបានធ្វើការចោទប្រកាន់ក្នុងទម្រង់មួយ ដែលមិនស្ទូវជាក់លាក់ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ គឺមិនទាក់ទងនឹងការវិភាគពីនីត្យានុកូលភាពទេ ព្រោះថាការប្រព្រឹត្តិដែលជាប្រធានបទនៃការរំលោភសេពសន្ថវៈនោះ គឺមានលក្ខណៈតែមួយដូចគ្នា"[៤៨]។ ការលើកឡើងរបស់សហព្រះរាជអាជ្ញានេះ មិនត្រឹមត្រូវឡើយ។ ដើម្បីឱ្យជនជាប់ចោទអាចប្រមើលដឹងថា បទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការរំលោភសេពសន្ថវៈត្រូវតែត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌមុនឆ្នាំ ១៩៧៥ ឬ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ថាជាអំពើមួយនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ ប្រសិនបើឧក្រិដ្ឋកម្មនៃអំពើរំលោភសេពសន្ថវៈ "ត្រូវបានធ្វើការចោទប្រកាន់នៅក្នុងទម្រង់មិនស្ទូវជាក់លាក់នៅក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩" ជាអាទិ៍មានដូចជាថា អំពើនៃការរំលោភសេពសន្ថវៈត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នោះជនជាប់ចោទគ្រាន់តែអាចប្រមើលមើលដឹងថាការចោទប្រកាន់មាន "ទម្រង់មិនស្ទូវជាក់ជាក់" បែបនេះតែប៉ុណ្ណោះ។ ដោយក្ដីគោរព មេធាវីការពារក្ដីយល់ស្របទៅនឹងការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដែលថា "ខណៈណាធាតុផ្សំនៃបទល្មើសទាំងពីរប្រភេទមិនដូចគ្នាទាំងស្រុងទេនោះ បទល្មើសជាតិ និងបទល្មើសអន្តរជាតិត្រូវបានចាត់ទុកថាជាបទល្មើស

---

[៤៨] សំណុំរឿង *Cyprus តទល់នឹង ប្រទេសទួរគី* ពាក្យសុំលេខ 6780/74 និងលេខ 6950/75 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៦ កថាខណ្ឌ ៣៧៤។

ពីរដាច់ពីគ្នា”[៤៩]។ ការរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ “ចាំបាច់ត្រូវមានធាតុផ្សំទាំងអស់ដូចឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវថា អំពើនោះគឺជាផ្នែកមួយនៃ ‘ការវាយប្រហារដោយរាលដាល ឬ ជាប្រព័ន្ធ’” ហើយជាលទ្ធផល ‘ការរំលោភសេពសន្ថវៈ ដូចដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិកំណត់និយមន័យនោះ មិនមានធាតុផ្សំបែបនេះទេ’[៥០]។

២៧. សហព្រះរាជអាជ្ញាបន្តអះអាងថា លក្ខខណ្ឌតម្រូវនៃ ‘ភាពអាចដឹងថាមានច្បាប់ចែង’ ត្រូវបានបំពេញ ដោយហេតុថា “ព័ត៌មានចាំបាច់ដែលត្រូវឈានដល់សេចក្ដីសន្និដ្ឋានថា បទរំលោភសេពសន្ថវៈ គឺអាចផ្ដន្ទាទោសបានក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ នៅក្នុងច្បាប់តាមទម្លាប់អន្តរជាតិ [...] គឺមានស្រាប់ជាសាធារណៈ និងដែលអាចរកបាន”[៥១]។ សហព្រះរាជអាជ្ញាមិនបានបង្ហាញឱ្យឃើញថា ជនជាប់ចោទអាចដឹងយ៉ាងងាយថាមានច្បាប់ចែង អំពីការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាពិសេសដោយសារសហព្រះរាជអាជ្ញាមិនបានផ្ដល់ឱ្យនូវឯកសារសំអាងផ្លូវច្បាប់ ដែលបង្ហាញថាការរំលោភសេពសន្ថវៈមានអត្ថិភាពជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិមួយដោយដាច់ដោយឡែក នៅមុនឆ្នាំ ១៩៧៥ ឬ នៅក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ ទឡ្ហីករណ៍លើ ភាពអាចដឹងថាមានច្បាប់ចែង មិនត្រូវបានគាំទ្រឡើយ។

២៨. សហព្រះរាជអាជ្ញាលើកឡើងជាជម្រើសម្យ៉ាងទៀតថា ប្រសិនបើមានភាពមិនច្បាស់លាស់ចំពោះថាតើការរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់នៅក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬទេនោះ “ដំណោះស្រាយលើភាពមិនច្បាស់លាសនោះតាមរយៈ

[៤៩] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៣។

[៥០] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ១៥៣។

[៥១] សាលដីការបស់ អ.ប.ជ កថាខណ្ឌ ១៥៣។

ការកំណត់សម្រេចតាមផ្លូវតុលាការ គឺអាចព្យាករណ៍ទុកជាមុនបាន"[៥២]។ សហព្រះរាជអាជ្ញា យោងទៅលើសំណុំរឿងនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប *SW តទល់នឹង ចក្រភពអង់គ្លេស* ដែលតុលាការនេះបានសម្រេចថា អភ័យឯកសិទ្ធិរបស់ស្វាមីឱ្យរួចផុតពីការចោទប្រកាន់ពីបទរំលោភភរិយារបស់ខ្លួន ត្រូវបានព្យាករណ៍ទុកជាមុនសម្រាប់គាត់ ដោយពិចារណាទៅលើ "ការអភិវឌ្ឍន៍ជឿនលឿន" នៃច្បាប់ដែលពាក់ព័ន្ធ[៥៣] "ការបង្ហាញយ៉ាងច្បាស់" ដែលពង្រីកការបកស្រាយដោយតុលាការទៅលើការប្រែប្រួលនៅក្នុងច្បាប់[៥៤] និងដោយពិចារណាទៅលើ "ការវិវឌ្ឍជាក់ស្តែង [...] នៃច្បាប់ព្រហ្មទណ្ឌ តាមរយៈការបកស្រាយតាមផ្លូវតុលាការ"[៥៥]។ សហព្រះរាជអាជ្ញាមិនបានបង្ហាញឱ្យឃើញថា ការអភិវឌ្ឍ ការបង្ហាញ និងការវិវឌ្ឍបែបទាំងនេះ មានវត្តមាននៅមុនឆ្នាំ ១៩៧៥ ឬនៅក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដើម្បីធ្វើឱ្យអំពើនៃការរំលោភសេពសន្ថវៈ អាចឱ្យគេយល់បានថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់។ មិនមានសេចក្តីសម្រេចតាមផ្លូវតុលាការណាមួយ ត្រូវបាន ឬអាចត្រូវបានព្យាករណ៍ទុកជាមុនបានដោយជនជាប់ចោទនៅក្នុងអំឡុងពេលនោះទេ។

២៩. នៅក្នុងការអះអាងថា ព័ត៌មានដែលថាការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ អាចឱ្យជនជាប់ចោទរកបាននោះ សហព្រះរាជអាជ្ញាគ្រាន់តែយោងទៅលើ "ចរិតលក្ខណៈជាក់ស្តែងយ៉ាងច្បាស់នៃអំពើនានាក្នុងបទរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[៥៦]។ មេធាវី

---

[៥២] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៤។

[៥៣] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៥។

[៥៤] សំណុំរឿង *S.W តទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំលេខ 20166/92 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៤០។

[៥៥] សំណុំរឿង *S.W តទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំលេខ 20166/92 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៤០។

[៥៦] សំណុំរឿង *S.W តទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំលេខ 20166/92 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៤៣។

ការពារក្ដីសូមច្រានចោលនូវការសំអាងរបស់សហព្រះរាជអាជ្ញាទៅលើចរិតលក្ខណៈនៃអំពើនានាក្នុងការគាំទ្រដល់សំណើរបស់ខ្លួន។ លោកចៅក្រម Justice Robertson (*រ៉ូប៊ឺតសាន់*) បានចង្អុលបង្ហាញនៅក្នុងមតិជំទាស់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការ STL ដូចខាងក្រោមថា៖

> […] នៅពេលដែលអំពើនានាមានលក្ខណៈគួរឱ្យស្អប់ខ្ពើម និងគួរឱ្យរន្ធត់យ៉ាងខ្លាំង វាមានភាពច្បាស់លាស់ថា យើងត្រូវតែអនុវត្តគោលការណ៍នីត្យានុកូលភាពឱ្យបានយ៉ាងម៉ឺងម៉ាត់ ដើម្បីធានាឱ្យបានថា ជនជាប់ចោទ នឹងមិនត្រូវបានសម្រេចថាមានទោស ដោយសារការស្អប់ខ្ពើមជាជាងដោយសារភស្តុតាង ឬក៏ដោយសារឧក្រិដ្ឋកម្មដែលមិនមានអត្ថិភាពនោះទេ[៥៧]។

៣០. បន្ថែមលើនេះ សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា បទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ក៏អាចឱ្យជនជាប់ចោទបានដឹងផងដែរ ដោយហេតុថាការរំលោភសេពសន្ថវៈ ត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់កម្ពុជា ហើយដូច្នេះ ជនជាប់ចោទ ប្រាកដជាយល់ដឹងអំពីលទ្ធភាពដែលថា ការទទួលខុសត្រូវខាងព្រហ្មទណ្ឌអន្តរជាតិ អាចមានចំពោះអំពើនានានៃបទរំលោភសេពសន្ថវៈ ដែលបានប្រព្រឹត្តក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៥៨]។ សហព្រះរាជអាជ្ញាក៏អះអាងបន្ថែមទៀតថា គោលការណ៍នីត្យានុកូលភាពត្រូវបានបំពេញ ដោយហេតុថាអំពើល្មើសព្រហ្មទណ្ឌនេះអាចត្រូវផ្ដន្ទាទោសបាន ដោយមិនពិចារណាថាតើបទចោទជាក់ស្ដែងត្រូវបានកំណត់ដោយរបៀបណានោះទេ[៥៩]។ ដូចបានលើកឡើងពីខាងលើរួចហើយ ការកំណត់ការរំលោភសេពសន្ថវៈថាជាបទល្មើសព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ថាជាបទល្មើសព្រហ្មទណ្ឌថ្នាក់ជាតិ មិនមានភាពពាក់ព័ន្ធឡើយ នៅពេលធ្វើការវាយ

---

[៥៧] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៥។

[៥៨] សំណុំរឿង *រដ្ឋអាជ្ញា ប្រឆាំងនឹង Sam Hinga Norman* ឯកសារ SCSL-04-14-AR72(E) របស់អង្គជំនុំជម្រះជាន់ខ្ពស់សាលាដីកាលើអញ្ញត្រកម្ម ដែលផ្អែកលើភាពគ្មានយុត្តាធិការ (ការជ្រើសរើសកុមារឱ្យធ្វើការ) មតិជំទាស់របស់ចៅក្រម Robertson ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ១២។

[៥៩] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៥។

តម្លៃថាតើជនជាប់ចោទ អាចបានព្យាករណ៍ទុកជាមុន និងយល់ដឹងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[៦០]។ បទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋថ្នាក់ជាតិ និងបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទល្មើសពីរដាច់ពីគ្នា។ សហព្រះរាជអាជ្ញាមិនអាចដាក់បញ្ចូលយ៉ាងងាយនូវបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋថ្នាក់ជាតិ ចូលទៅក្នុងជំពូកនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិបានឡើយ។ ការធ្វើបែបនេះ នឹងរំលោភបំពានលើគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង (*nullem crimen sine lege*) ដោយហេតុថា បទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិមិនមានអត្ថិភាពនៅក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។

៣១. នៅចុងបញ្ចប់ សហព្រះរាជអាជ្ញាអះអាងថា ការចោទប្រកាន់ជនជាប់ចោទពីបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ នឹងមាន "ប្រយោជន៍បន្ទាប់បន្សំនៃការធ្វើវិភាគទានដល់កំណត់ត្រាប្រវត្តិសាស្ត្រនៃករណីនេះ តាមរយៈការចាត់ឱ្យមានការចោទប្រកាន់នានា តាមរបៀបមួយដែលមានលក្ខណៈច្បាស់លាស់ជាង និងងាយយល់ជាង ចំពោះសមាជិកនានានៃសាធារណជនទូទៅ"[៦១]។ មេធាវីការពារក្តីសូមលើកឡើងថា ជនជាប់ចោទមិនអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ដែលមិនមានអត្ថិភាពនៅក្នុងអំឡុងពេលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត គ្រាន់តែដើម្បីផលប្រយោជន៍នៃកំណត់ត្រាប្រវត្តិសាស្ត្រនោះទេ។ ទឡ្ហីករណ៍មួយនេះត្រូវបានធ្វើឡើងដោយមិនពិចារណាទៅលើនីតិរដ្ឋ និងទៅលើបទប្បញ្ញត្តិនានានៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយដូច្នេះ គួរតែត្រូវបានបដិសេធចោល។

### ៤.២.៣ តើអង្គហេតុនានានៅក្នុងដីកាដំណោះស្រាយ ផ្តល់ឱ្យជាមូលដ្ឋានគ្រប់គ្រាន់មួយ សម្រាប់យល់ឃើញថា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើរំលោភសេពសន្ថវៈ ត្រូវបានប្រព្រឹត្តដែរឬទេ

---

[៦០] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៦។

[៦១] សូមមើលការឆ្លើយតបរបស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ កថាខណ្ឌ ៤៨។

៣២. តាមរយៈអង្គហេតុនានាដែលត្រូវបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ និងសារណាស្ដាពររបស់ខ្លួន សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការចោទប្រកាន់ជនជាប់ចោទពីបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលមិនមែនជាបទរំលោភសេពសន្ថវៈនៅក្នុងការរៀបការដោយបង្ខំ ដែលមានឋានៈជាអំពើអមនុស្សធម៌ដទៃទៀតមួយនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិឡើយ[៦២]។

៣៣. មេធាវីការពារក្ដីសូមអះអាងថា អង្គហេតុនានាទាំងនោះមិនមានភាពពាក់ព័ន្ធទេ នៅពេលធ្វើការសម្រេចថាតើជនជាប់ចោទគួរតែត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈក្នុងឋានៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬក៏បទរំលោភសេពសន្ថវៈក្នុងឋានៈជាអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ។ បញ្ហាចំពោះមុខនោះគឺជាការគោរពគោលការណ៍នីត្យានុកូលភាពជាសារវ័ន្ត។ មិនថាអង្គហេតុបែបណាមាននៅក្នុងដីកាដំណោះស្រាយឡើយ ក៏ការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដោយឧក្រិដ្ឋកម្មមិនមានអត្ថិភាពនៅក្នុងអំឡុងពេលវេលាដែលពាក់ព័ន្ធ នឹងជាការរំលោភបំពានលើគោលការណ៍ជាសារវ័ន្តមួយនេះ។

៣៤. នៅក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែ ជនជាប់ចោទត្រូវបានចោទពីបទរំលោភសេពសន្ថវៈនៅក្នុងការរៀបការដោយបង្ខំ ថាជាអំពើអមនុស្សធម៌ដទៃទៀត។ មេធាវីការពារក្ដីបានប្រឆាំងជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក លើបទល្មើសព្រហ្មទណ្ឌមួយនេះ នៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ ហេតុដូចនេះ មេធាវីការពារក្ដីសូមយោងទៅលើសារណាពីមុននានារបស់ខ្លួន ដែលក្នុងសារណាទាំងនោះ មេធាវីការពារក្ដីលើកជាទឡ្ហីករណ៍ថាបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈនៅក្នុងការរៀបការដោយបង្ខំក្នុងឋានៈជាអំពើអមនុស្សធម៌ដទៃទៀតនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ មិនត្រូវបានបញ្ជាក់ឱ្យជាក់លាក់គ្រប់គ្រាន់នៅក្នុងដីកាដំណោះស្រាយនោះទេ ហើយថាការធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌមួយនេះ មិន

---

[៦២] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៨។

ត្រូវបានព្យាករណ៍ទុកជាមុននោះដែរ[៦៣]។ ត្រង់ចំណុចនេះ មេធាវីការពារក្ដីសូមអនុម័តនូវទទ្បីករណ៍ដូចគ្នាទាំងនេះចំពោះអង្គហេតុនានា ដែលយកមកធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់បទរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ ជាថ្មីម្ដងទៀត មេធាវីការពារក្ដីសូមអះអាងថា សារណារបស់សហព្រះរាជអាជ្ញាគួរតែត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថាជាបញ្ហាយុត្តាធិការ ប៉ុន្តែវាហួសពេលរួចទៅហើយនាពេលនេះ ហើយដូច្នេះ សារណានេះមិនគួរត្រូវបានគិតគូរនោះទេ។

## V. សេចក្ដីសន្និដ្ឋាន

៣៥. សម្រាប់សំអាងហេតុដូចបានរៀបរាប់ពីខាងលើ មេធាវីការពារក្ដីសូមស្នើដោយគោរពឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(i) យល់ឃើញថា សំណើរបស់ ក.ស.ព មិនអាចទទួលយកបានទេ។

(ii) ឬ បើមិនដូច្នេះទេ បដិសេធចោលសំណើរបស់ ក.ស.ព ទាំងស្រុងតែម្ដង។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ លោកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ | ផាត់ ពៅ ស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | |

[៦៣] សំណើរបស់ ក.ស.ព កថាខណ្ឌ ២៩ ដល់កថាខណ្ឌ ៣៣។